**UNITED NATIONS**
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

**NATIONS UNIES**
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

**អង្គការសហប្រជាជាតិ**
**ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា**

COHCHR

# សេចក្តីថ្លែងការណ៍របស់លោកស្រី លូអ៊ីស អាបើ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

ភ្នំពេញ ថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០០៦

ខ្ញុំមានកិត្តិយសណាស់ ដែលបានធ្វើទស្សនកិច្ចលើកដំបូងមកកាន់ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលការិយាល័យខ្ញុំបានប្រតិបត្តិការអស់រយៈពេលជាងមួយទសវត្សហើយរហូតមកទល់ពេលបច្ចុប្បន្ននេះ ។ ខ្ញុំបានទទួលបុព្វសិទ្ធិដែលបានការអនុញ្ញាតចូលគាល់ព្រះមហាក្សត្រ ហើយខ្ញុំបានជួបជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន, លោក ស ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, លោក សុខ អាន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី, លោក អង្គ វង្សវឌ្ឍនា រដ្ឋមន្ត្រីក្រសួង យុត្តិធម៌ ។ ខ្ញុំក៏បានជួបជាមួយតំណាងជាច្រើននៃអង្គការសង្គមស៊ីវិល ក្រុមអង្គការសហប្រជាជាតិនៅកម្ពុជា សមាជិកនានានៃសហគមន៍អ្នកការទូត និងមន្ត្រីមួយចំនួននៃអង្គជំនុំជំរះវិសាមញ្ញ ដើម្បីកាត់សេចក្តីមេដឹកនាំខ្មែរក្រហម ។

ដំណើរទស្សនកិច្ចនេះ បានផ្តល់ឱកាសឱ្យខ្ញុំបានស្វែងយល់ច្រើនថែមទៀត អំពីសភាពការណ៍សិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ។ គេបានប្រាប់ខ្ញុំជាច្រើនលើកអំពីការវិវឌ្ឍជាវិជ្ជមាននៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ១៩៩៣ មក រួមមានអំពីស្ថិរភាពបន្ទាប់ពីមានជំលោះរយៈពេលជាច្រើនឆ្នាំមក ការរីកចំរើនខាងសេដ្ឋកិច្ច និងការរៀបចំការបោះឆ្នោតជាទៀងទាត់ ។ ជាការពិតណាស់ មិនមានប្រទេសណាមួយដែលមានកំណត់ហេតុសិទ្ធិមនុស្សល្អឥតខ្ចោះនោះទេ ។ ខ្ញុំជឿជាក់ថា សញ្ញាណមួយដែលល្អសំរាប់ការរីកចំរើននោះគឺសមត្ថភាពក្នុងការទទួលស្គាល់នូវអ្វីដែលជាចំណុចខ្វះខាត ។ សភាពការណ៍សិទ្ធិមនុស្សនៅកម្ពុជា គឺជាកម្មវត្ថុនៃការវិភាគជាទូទៅដោយតំណាងពិសេសនៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ចំនួនបួនរូបបន្តបន្ទាប់គ្នា ។ សេចក្តីសង្កេតរបស់ពួកគាត់បង្ហាញពីការលំបាកជាច្រើននៅក្នុងប្រទេសនេះ ដែលមិនទាន់ជំនះបាននៅឡើយ ។

ដំណើរទស្សនកិច្ចនេះ ក៏បានអនុញ្ញាតឱ្យខ្ញុំផ្តោតទៅលើបញ្ហាមួយ ដែលខ្ញុំគិតថាមានសារៈសំខាន់សំរាប់ការពង្រឹងលិទ្ធិប្រជាធិបតេយ្យ ក្រោមនីតិរដ្ឋដែលគេហៅថា ការពង្រឹងការគ្រប់គ្រងប្រព័ន្ធតុលាការ ។ ប្រព័ន្ធតុលាការមួយដែលប្រកបដោយវិជ្ជាជីវៈ និងឯករាជ្យ ដែលគេទទួលស្គាល់ថាមានសុច្ចរិតភាព ដែលនេះមិនត្រឹមតែមានសារៈសំខាន់ក្នុងការការពារសិទ្ធិសេរីភាពជាមូលដ្ឋានប៉ុណ្ណោះទេ តែថែមទាំងអាចជួយដោះស្រាយនូវការលំបាកជាច្រើនដែលមាននៅក្នុងប្រទេសកម្ពុជា រួមទាំងបញ្ហានីទណ្ឌភាព ជំលោះដីធ្លី និងអំពើពុករលួយ ។

លទ្ធភាពរបស់សមាជិកសង្គមស៊ីវិល ក្នុងការបំពេញមុខងាររបស់ខ្លួនដោយសេរី និងដោយសុវត្ថិភាពក៏ជាសូចនាករជាគន្លឹះមួយទៀតផងដែរ សំរាប់ការប្រព្រឹត្តិទៅនៃលិទ្ធិប្រជាធិបតេយ្យ ។ ជំនាញវិជ្ជាជីវៈ និងការប្តេជ្ញាចិត្តរបស់អង្គការក្រៅរដ្ឋាភិបាលនានា គឺជាពិតជាមរតកមួយដែលមានតំលៃសំរាប់ការអភិវឌ្ឍន៍ប្រទេសកម្ពុជា ហើយក៏ជាមរតកមួយដែលត្រូវទទួលបានការ ធានាការពារ និងគាំទ្រផងដែរ ។

ដំណើរទស្សនកិច្ចរបស់ខ្ញុំមកប្រទេសកម្ពុជា ធ្វើឡើងនៅក្នុងខណៈពេលដែលប្រព័ន្ធសិទ្ធិមនុស្សពិភពលោកមានការប្រែប្រួលយ៉ាងច្រើន ។ អង្គការអន្តររដ្ឋាភិបាលថ្មីមួយ ដែលមានឈ្មោះថា ក្រុមប្រឹក្សាសិទ្ធិមនុស្ស នឹងបើកកិច្ចប្រជុំលើកដំបូងរបស់ខ្លួននៅខែក្រោយនេះ ។ ក្រុមប្រឹក្សានេះនឹងចាត់ចែងការងារជាច្រើនរបស់ខ្លួន រួមមានការពិនិត្យឡើងវិញរាល់របាយការណ៍សិទ្ធិមនុស្សរបស់រដ្ឋសមាជិកទាំងអស់របស់អង្គការសហប្រជាជាតិ ។ ម្យ៉ាងវិញទៀត វាច្បាស់ណាស់ដែលថាសភាពការណ៍សិទ្ធិមនុស្សនៅក្នុងប្រទេសនីមួយៗ គឺជាការព្រួយបារម្ភស្របច្បាប់របស់សហគមន៍អន្តរជាតិ ។ ចំពោះបញ្ហានេះ ខ្ញុំបានទទួលការធានាពីរដ្ឋាភិបាលនៃប្រទេសកម្ពុជា ដោយការប្តេជ្ញាចិត្តពង្រឹងកិច្ចសហប្រតិបត្តិការរយៈពេលយូរអង្វែង និងការប្តេជ្ញាចិត្តអនុវត្តការងាររបស់យើងឱ្យទទួលបានអត្ថប្រយោជណ៍ជាក់ស្តែងសំរាប់ការការពារសិទ្ធិមនុស្សនៅកម្ពុជា ។

#10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587
E-mail: cohchr@online.com.kh Website: http://cambodia.ohchr.org